# គោលការណ៍ណែនាំសំរាប់អនុវត្តមាត្រា ១១
# (ការវេចខ្ចប់ និងការបិទផ្លាកលើផលិតផលថ្នាំជក់)
# នៃអនុសញ្ញាស្តីពីការត្រួតពិនិត្យថ្នាំជក់ របស់អង្គការសុខភាពពិភពលោក

## គោលបំណង គោលការណ៍ និងការប្រើពាក្យ

### គោលបំណង

១. ស្របតាមបទបញ្ញត្តិនៃអនុសញ្ញាស្តីពីការត្រួតពិនិត្យថ្នាំជក់ របស់អង្គការសុខភាពពិភពលោក និងបំណងរបស់សន្និសីទភាគីនៃអនុសញ្ញា គោលការណ៍ណែនាំនេះ មានបំណងជួយដល់ភាគីទាំងឡាយក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួន ដោយអនុលោមតាមមាត្រា ១១ នៃអនុសញ្ញា និងស្នើសុំឱ្យមានវិធានការនានាដែលភាគីទាំងឡាយអាចប្រើប្រាស់បាន ក្នុងការបង្កើនប្រសិទ្ធភាពនៃវិធានការវេចខ្ចប់ និងបិទផ្លាករបស់ខ្លួន។ មាត្រា ១១ ចែងថា ភាគីនិមួយៗ ត្រូវបង្កើត និងអនុវត្តវិធានការក្នុងការវេចខ្ចប់ និងបិទផ្លាក ឱ្យបានក្នុងរយៈពេល៣ឆ្នាំ បន្ទាប់ពីអនុសញ្ញាបានចូលជាធរមានសំរាប់ភាគីនោះ ។

### គោលការណ៍

២. ដើម្បីសំរេចបាននូវគោលដៅនៃអនុសញ្ញា និងពិធីសាររបស់វា ហើយនិងដើម្បីធានាបាននូវការអនុវត្តន៏ប្រកបដោយប្រសិទ្ធភាពនូវបញ្ញត្តិរបស់វា មាត្រា ៤ នៃអនុសញ្ញាចែងថា ភាគីទាំងឡាយត្រូវទទួលការណែនាំជាអាទិ៏ នូវគោលការណ៏ដែលថា ជនគ្រប់រូបត្រូវទទួលបានព័ត៌មានអំពីផលប៉ះពាល់ដល់សុខភាព សភាពនៃការញៀន និងការគំរាមកំហែងដល់ជីវិតបណ្តាលមកពីការប្រើប្រាស់ថ្នាំជក់ និងការរងផ្សែងថ្នាំជក់។

៣. នៅទូទាំងសកលលោក មនុស្សជាច្រើនមិនបានយល់ដឹង ភាន់ច្រឡំ ឬក៏មើលស្រាលទៅលើគ្រោះថ្នាក់នៃជម្ងឺ និងការស្លាប់មុនអាយុកាលដោយសារការប្រើប្រាស់ថ្នាំជក់ និងការរងនូវផ្សែងថ្នាំជក់ បំរាមសុខភាព និងសារនៅលើកញ្ចប់បារីដែលគេរៀបរៀងឡើងយ៉ាងល្អ ត្រូវបានគេបង្ហាញឱ្យឃើញថា ជាមធ្យោបាយមានប្រសិទ្ធភាពខ្ពស់ ក្នុងការបង្កើនការយល់ដឹងពីផលប៉ះពាល់ដល់សុខភាព បណ្តាលមកពីការប្រើប្រាស់ថ្នាំជក់ និងមានប្រសិទ្ធភាពក្នុងការកាត់បន្ថយការប្រើប្រាស់ថ្នាំជក់។ បំរាមសុខភាព និងសារ ព្រមទាំងវិធានការវេចខ្ចប់ និងបិទផ្លាកលើផលិតផលថ្នាំជក់ដែលមានប្រសិទ្ធភាពនានា គឺជាសមាសធាតុនៃវិធីសាស្ត្រដែលពេញលេញ និងរួមបញ្ចូលគ្នាក្នុងការត្រួតពិនិត្យថ្នាំជក់។

៤. ភាគីទាំងឡាយគួរពិចារណាលើភស្តុតាង និងបទពិសោធន៏នៃភាគីដទៃ ដើម្បីកំណត់វិធានការវេចខ្ចប់ និងបិទផ្លាក និងលើការអនុវត្តន៏វិធានការដែលមានប្រសិទ្ធភាពបំផុត ដែលភាគីទាំងនោះអាចសំរេចបាន។

៥. ដូចមានចែងក្នុងមាត្រា ២០ និង ២២ នៃអនុសញ្ញា កិច្ចសហប្រតិបត្តិការអន្តរជាតិ និងការគាំទ្រគ្នាទៅវិញទៅមក គឺជាគោលការណ៍គ្រឹះ សំរាប់ពង្រឹងសមត្ថភាពភាគីទាំងឡាយ ក្នុងការអនុវត្តន៍យ៉ាងពេញទំហឹង និងធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាពនៃមាត្រា ១១ នៃអនុសញ្ញា។

## ការប្រើពាក្យ

៦. សំរាប់គោលបំណងនៃគោលការណ៍ណែនាំនេះ :

"វិធានការស្របច្បាប់" សំដៅលើឧបករណ៍ផ្នែកច្បាប់ ដែលផ្ទុក ឬបង្កើតនូវកាតព្វកិច្ច ការទាមទារ ឬការហាមឃាត់ ដោយយោងទៅតាមច្បាប់នៃយុត្តាធិការដែលពាក់ព័ន្ធ។ ឧទាហរណ៍នៃឧបករណ៍ទាំងនេះរួមមាន ប៉ុន្តែមិនកំណត់ចំពោះតែ ច្បាប់ បទបញ្ជា និងសេចក្តីបង្គាប់រដ្ឋបាល ឬប្រតិបត្តិ

"ព័ត៌មានដាក់បញ្ចូលខាងក្នុង" មានន័យថា ព័ត៌មាននៅផ្នែកខាងក្នុងនៃកញ្ចប់និមួយៗ និង/ឬសុង ដែលអតិថិជនទិញនៅកន្លែងលក់រាយ ដូចជា ខិតប័ណ្ណ ឬសន្លឹកប័ណ្ណដែលមានរូបភាពតូចៗ។

"ព័ត៌មានខាងក្រៅ" មានន័យថា ព័ត៌មានដែលបិទនៅផ្នែកខាងក្រៅនៃកញ្ចប់និមួយៗ និង/ឬសុង ដែលអតិថិជនទិញនៅកន្លែងលក់រាយ ដូចជាសន្លឹកប័ណ្ណដែលមានរូបភាពតូចៗនៅពីក្រោយនៃផ្នែកខាងក្រៅនៃក្រដាសភ្លឺដែលខ្ចប់ ឬបិទជាប់ទៅផ្នែកខាងក្រៅនៃកញ្ចប់បារី។

## ការបង្កើតឡើងនូវការទាមទារឱ្យមានការវេចខ្ចប់ និងបិទស្លាកយ៉ាងមានប្រសិទ្ធភាព

៧. បំរាមសុខភាព និងសារដែលរៀបចំឡើងយ៉ាងល្អ គឺជាផ្នែកនៃវិធានការ ដ៏មានប្រសិទ្ធភាពទាំងឡាយ ក្នុងការផ្តល់ព័ត៌មានពីគ្រោះថ្នាក់ដល់សុខភាព និងកាត់បន្ថយការប្រើប្រាស់ថ្នាំជក់។ ភស្តុតាងបង្ហាញថា ប្រសិទ្ធភាពនៃបំរាមសុខភាព និងសារ មានការកើនឡើងជាមួយនឹងភាពលេចធ្លោរបស់វា។ បើធៀបជាមួយនឹងបំរាមសុខភាពដែលមានត្រឹមតែអក្សរតូចៗនោះ បំរាមដែលមានទំហំធំដោយមានរូបភាព មានភាពគួរឱ្យចាប់អារម្មណ៍ជាង ផ្តល់ព័ត៌មានពីគ្រោះថ្នាក់ដល់សុខភាពបានល្អជាង ញ៉ាំងឱ្យមានការរំជួលចិត្តច្រើនជាង និងបង្កើនការជំរុញអ្នកជក់បារីឱ្យលះបង់ ឬបន្ថយការប្រើប្រាស់ថ្នាំជក់ច្រើនជាង។ បំរាមសុខភាពជារូបភាពកាន់តែធំ កាន់តែធានាបាននូវប្រសិទ្ធភាពបានយូរ និងមានប្រសិទ្ធភាពជាពិសេសក្នុងការផ្តល់ព័ត៌មានពីផលប៉ះពាល់ដល់សុខភាពទៅដល់ប្រជាពលរដ្ឋ ដែលមានចំណេះដឹងទាប កុមារ និងមនុស្សវ័យក្មេង។ កត្តាផ្សេងទៀតដែលបង្កើនប្រសិទ្ធភាព រួមមានការដាក់បំរាមសុខភាព និងសារលើផ្ទៃសំខាន់ និងនៅផ្នែកខាងលើនៃផ្ទៃសំខាន់ទាំងនេះ ការប្រើពណ៌ធម្មជាតិជាជាងពណ៌សខ្មៅ ការទាមទារឱ្យមានបំរាមសុខភាព និងសារឆ្លាស់គ្នា និងការពិនិត្យឡើងវិញជាប្រចាំ នូវបំរាមសុខភាព និងសារទាំងនោះ ។

**ការរៀបចំ**

៨. មាត្រា ១១.១(ខ)(iii) នៃអនុសញ្ញា បញ្ជាក់ច្បាស់ថា ភាគីនីមួយៗត្រូវអនុម័ត និងអនុវត្តនូវវិធានការមានប្រសិទ្ធភាពដើម្បីធានាថា បំរាមសុខភាព និងសារត្រូវតែមានទំហំធំ ច្បាស់លាស់ មើលឃើញច្បាស់ និងអាចអានបាន។ ទីតាំង និងការដាក់តំរៀបបំរាមសុខភាព និងសារលើកញ្ចប់បារីត្រូវធានាឱ្យបានជាអតិបរមានូវភាពដែលអាចមើលឃើញច្បាស់។ ការស្រាវជ្រាវបង្ហាញថា បំរាមសុខភាព និងសារ ដែលដាក់នៅផ្នែកខាងលើ អាចមើលឃើញច្បាស់ជាងដាក់នៅផ្នែកខាងក្រោម នៃផ្នែកខាងមុខ និងក្រោយនៃកញ្ចប់។ ភាគីទាំងឡាយ ត្រូវទាមទារឱ្យមានបំរាម និងសារត្រូវស្ថិតនៅទីតាំង :

ទាំងផ្នែកខាងមុខ និងខាងក្រោយ (ឬនៅលើផ្ទៃសំខាន់ ប្រសិនបើមានផ្ទៃលើសពីពីរ) នៃសំណុំ និងកញ្ចប់ ជាជាងគ្រាន់តែដាក់នៅលើតែមួយជ្រុង ដើម្បីធានាឱ្យបានថា បំរាមសុខភាព និងសារត្រូវបានគេមើលឃើញយ៉ាងច្បាស់ ដោយទទួលស្គាល់ថា ផ្ទៃខាងមុខគឺជាកន្លែងដែលអតិថិជនអាចមើលឃើញច្បាស់ជាងគេ ចំពោះប្រភេទកញ្ចប់ភាគច្រើន

នៅលើផ្ទៃសំខាន់ និងជាពិសេសផ្នែកខាងលើនៃផ្ទៃសំខាន់ ជាជាងនៅផ្នែកខាងក្រោម ដើម្បីបង្កើនការមើលឃើញច្បាស់ និង

ដោយមធ្យោបាយណា ដែលរាល់ការបើកកញ្ចប់ មិនធ្វើឱ្យខូចខាត ឬលុបអក្សរ ឬរូបភាព នៃបំរាមសុខភាពនោះ។

៩. ភាគីទាំងឡាយត្រូវពិចារណាការទាមទារការដាក់បន្ថែមបំរាមសុខភាព និងសារ ដូចមានចែងក្នុងល្បះទី៨ នៅលើគ្រប់ជ្រុងនៃកញ្ចប់បារី ក៏ដូចជានៅលើព័ត៌មានដាក់បញ្ចូលខាងក្នុង និងព័ត៌មានខាងក្រៅ។

១០. ភាគីទាំងឡាយត្រូវធានាថា បំរាមសុខភាព និងសារ មិនត្រូវបានបិទបាំងដោយកំណត់សំគាល់ការវេចខ្ចប់ និងផ្លាកផ្សេង ឬដោយព័ត៌មានបញ្ចូលខាងក្នុង និងព័ត៌មានខាងក្រៅឡើយ។ ភាគីទាំងឡាយ ក៏ត្រូវធានាថា នៅពេលបង្កើតទំហំ និងទីតាំងនៃកំណត់សំគាល់ដទៃទៀត ដូចជាតែមស៏ពន្ធ និងកំណត់ចំណាំដូចការទាមទារដោយមាត្រា១៥នៃអនុសញ្ញា កំណត់សំគាល់ទាំងនេះមិនត្រូវបិទបាំងផ្នែកណាមួយនៃបំរាមសុខភាព និងសារឡើយ។

១១. ភាគីទាំងឡាយត្រូវពិចារណារិះរកវិធានការថ្មីទាក់ទងទៅនឹងទីតាំង រួមបញ្ចូល ប៉ុន្តែមិនកំណត់ចំពោះតែការទាមទារឱ្យមានការបោះពុម្ពបំរាមសុខភាព និងសារលើកន្ទុយស្នោរ ក្រដាសរុំពីក្រៅបារី និង/ឬលើសម្ភារៈដែលទាក់ទង ដូចជាកញ្ចប់បារី កន្ទុយស្នោរ ក្រដាស ក៏ដូចជាឧបករណ៍ផ្សេងៗទៀត ដូចជាឧបករណ៍ប្រើប្រាស់សំរាប់ការជក់ខ្សៀរទឹក។

**ទំហំ**

១២. មាត្រា ១១.១(ខ)(iv) នៃអនុសញ្ញា បញ្ជាក់ច្បាស់ថា បំរាមសុខភាព និងសារលើការវេចខ្ចប់ និងការបិទផ្លាកលើផលិតផលថ្នាំជក់ គួរតែមានទំហំ ៥០% ឬធំជាងនេះ ប៉ុន្តែវាត្រូវតែមិនអាចតូចជាង ៣០% នៅលើផ្ទៃសំខាន់ឡើយ ។ ដោយសារតែភស្តុតាងដែលថា ប្រសិទ្ធភាពនៃបំរាមសុខភាព និងសារ កើនឡើងទៅតាមទំហំរបស់វា ភាគីទាំងឡាយ គួរពិចារណាទៅលើការប្រើប្រាស់បំរាមសុខភាព និងសារដែលគ្របដណ្តប់លើ ៥០% នៃសំខាន់បំផុត និងមានបំណងគ្របដណ្តប់លើផ្ទៃសំខាន់ ឱ្យបានធំបំផុតតាមដែលអាចធ្វើបាន។ អក្សរនៃបំរាមសុខភាព និងសារ គួរតែបោះពុម្ពជាតួអក្សរដិត ក្រាស់ និងទំហំអក្សរអាចអានបាន និងមានរចនាបទជាក់លាក់ ព្រមទាំងពណ៌ធម្មជាតិ ដែលបង្កើនភាពមើលឃើញ និងអានបានច្បាស់ ។

១៣. ប្រសិនបើតំរូវឱ្យមានគែម ភាគីទាំងឡាយ មិនគួរទទួលយកនូវលំហសំរាប់ស៊ុមនៃបំរាមសុខភាព និងសារដែលបង្រួមទំហំនៃបំរាមសុខភាព និងសារនោះឡើយ នៅពេលដែលគេគណនារកភាគរយនៃផ្ទៃសំខាន់ដែលគ្របដណ្តប់ដោយបំរាមសុខភាព។ លំហសំរាប់ស៊ុមមិនត្រូវគិតបញ្ចូលក្នុងភាគរយនៃបំរាមសុខភាព និងសារទេ ។

**ការប្រើរូបភាព**

១៤. មាត្រា ១១.១(ខ)(v) នៃអនុសញ្ញា បញ្ជាក់ច្បាស់ថា បំរាមសុខភាព និងសារលើការវេចខ្ចប់ និងការបិទផ្លាកផលិតផលថ្នាំជក់ អាចស្ថិតក្នុងទំរង់ជា ឬរួមបញ្ចូលរូបភាព ឬជាលេខ។ ភស្តុតាងបានបញ្ជាក់ថា បំរាមសុខភាព និងសារដែលមានទាំងរូបភាព និងអក្សរមានប្រសិទ្ធភាពជាងបំរាមសុខភាព និងសារដែលមានតែអក្សរ ឆ្ងាយណាស់ ។ វាក៏មានផលប្រយោជន៍បន្ថែម ដល់ការជ្រួតជ្រាបជាសក្តានុពលដល់ប្រជាពលរដ្ឋ ដែលមានការយល់ដឹងទាប និងអ្នកដែលមិនអាចអានភាសានៃអក្សរដែលសរសេរនៅលើបំរាមសុខភាព ឬសារ ។ ភាគីទាំងឡាយ គួរដាក់បំរាមសុខភាពជារូបភាព វត្ថុលេខនា ជាពណ៌ធម្មជាតិដែលស្របទៅតាមវប្បធម៌របស់ខ្លួន នៅក្នុងការទាមទារឱ្យមានចំពោះការវេចខ្ចប់ និងការបិទផ្លាក។ ភាគីទាំងឡាយគួរតែគិតគូរដល់ការប្រើប្រាស់បំរាមសុខភាពជារូបភាព នៅលើផ្ទៃសំខាន់ទាំងពីរ (ឬនៅផ្នែកសំខាន់ ប្រសិនបើមានផ្ទៃលើសពីពីរ) នៃការវេចខ្ចប់ផលិតផលថ្នាំជក់ ។

១៥. ភស្តុតាងបង្ហាញថា នៅពេលដែលធ្វើការប្រៀបធៀបជាមួយនឹងបំរាមសុខភាព និងសារដែលមានតែអក្សរ បំរាមសុខភាព និងសារដែលមានរូបភាព :

ងាយស្រួលសំគាល់ជាង

មានប្រសិទ្ធភាពលើអ្នកជក់ជាង

លេចធ្លោជាង

ផ្តល់ព័ត៌មានពីគ្រោះថ្នាក់នៃការប្រើប្រាស់ថ្នាំជក់បានល្អជាង

បង្កើនហេតុផល និងចេតនាក្នុងការផ្តាច់ជាង ហើយ

ទាក់ទាញឱ្យព្យាយាមឈប់ជក់ច្រើនជាង

១៦. បំរាមសុខភាព និងសារព្រមានសុខភាពទាំងនេះ ក៏អាចបង្អាក់ឥទ្ធិពលនៃនិមិត្តរូបម៉ាកសញ្ញានៅលើការវេចខ្ចប់ និងកាត់បន្ថយភាពទាក់ទាញនៃកញ្ចប់ ។

១៧. នៅពេលបង្កើតរូបភាព សំរាប់ប្រើប្រាស់នៅលើកញ្ចប់ផលិតផលថ្នាំជក់ ភាគីទាំងឡាយគួរទទួល ដែលអាចធ្វើទៅបាន នូវភាពជាម្ចាស់ ឬកម្មសិទ្ធិចំលងនៃរូបភាពទាំងស្រុង ជាជាងការផ្តល់ឱ្យអ្នករចនា ឬប្រភពដទៃទៀត នូវកម្មសិទ្ធចំលងនេះ។ ការធ្វើបែបនេះ ផ្តល់នូវភាពបត់បែនជាអតិបរមា ក្នុងការប្រើប្រាស់រូបភាពសំរាប់ការធ្វើអន្តរាគមន៍ត្រួតពិនិត្យថ្នាំជក់ផ្សេងទៀត រួមមានយុទ្ធនាការបណ្តាញផ្សព្វផ្សាយព័ត៌មានចំរុះ និងនៅលើអ៊ីនធឺណេត។ វាក៏អាចធ្វើឱ្យភាគីទាំងឡាយ អាចផ្តល់អាជ្ញាប័ណ្ណដល់យុត្តាធិការក្នុងការប្រើប្រាស់រូបភាពទាំងនេះ។

## លក្ខណៈពណ៌

១៨. ការប្រើប្រាស់ពណ៌ ដោយផ្ទុយពីពណ៌សខ្មៅ មានឥទ្ធិពលដល់ការសំគាល់ជាទូទៅនៃធាតុរបស់បំរាមសុខភាព និងសារ។ ដូច្នេះភាគីទាំងឡាយ គួរតែទាមទារឱ្យមានពណ៌ធម្មជាតិពេញលេញ (ពណ៌សំរាប់បោះពុម្ពទាំងបួន) ជាជាងពណ៌សខ្មៅសំរាប់ធាតុរូបភាពនៃបំរាមសុខភាព និងសារ។ ភាគីទាំងឡាយ គួរជ្រើសរើសពណ៌ដែលផ្ទុយ សំរាប់ដាក់លើផ្ទៃខាងក្រោយនៃអក្សរដើម្បីឱ្យងាយសំគាល់ឃើញ និងធ្វើឱ្យធំជាអតិបរមានូវអក្សរនៃបំរាមសុខភាព និងសារ។

## លក្ខណៈឆ្លាស់គ្នា

១៩. មាត្រា ១១.១(ខ)(v) នៃអនុសញ្ញា ចែងថា បំរាមសុខភាព និងសារត្រូវតែឆ្លាស់គ្នា ភាពឆ្លាស់គ្នានេះអាចអនុវត្តទៅបានដោយមានបំរាមសុខភាព និងសារជាច្រើនដាក់ដំណាលគ្នា ឬដោយដាក់កាលបរិច្ឆេទ សំរាប់ផ្លាស់ប្តូរបំរាមសុខភាព និងសារទាំងនោះ។ ភាគីទាំងឡាយ គួរគិតគូរអំពីការប្រើប្រាស់ភាពឆ្លាស់គ្នាទាំងពីរនេះ។

២០. ប្រសិទ្ធភាពប្លែកៗគ្នានៃបំរាមសុខភាព និងសារថ្មី មានសារសំខាន់ណាស់ ដោយភស្តុតាងបានស្នើឡើងថា ឥទ្ធិពលនៃបំរាមសុខភាព និងសារដដែលៗមានទំនោរថយចុះតាមពេលវេលា ដូច្នេះការផ្លាស់ប្តូរបំរាមសុខភាព និងសារមានទំនាក់ទំនងទៅនឹងការបង្កើនប្រសិទ្ធភាព។ ការដាក់ឆ្លាស់គ្នានៃបំរាមសុខភាព និងសារ និងការប្តូរទីតាំង និងការរចនា ផ្តល់សារសំខាន់ក្នុងការរក្សាបាននូវភាពលេចធ្លោ និងបង្កើនប្រសិទ្ធភាពរបស់វា។

២១. ភាគីទាំងឡាយ គួរកំណត់ឱ្យជាក់លាក់នូវចំនួនបំរាមសុខភាព និងសារ ដែលត្រូវមានក្នុងពេលបច្ចុប្បន្ន។ ភាគីទាំងឡាយ គួរតែទាមទារផងដែរឱ្យមានបំរាមសុខភាព និងសារនៅក្នុងស៊េរីជាក់លាក់ណាមួយ ត្រូវបានគេបោះពុម្ព ដើម្បីឱ្យបំរាមសុខភាព និងសារនិមួយៗមាននៅលើកញ្ចប់បារីលក់រាយចំនួនស្មើៗគ្នា មិនមែនគ្រាន់តែមានចំពោះក្រុមម៉ាកសញ្ញានិមួយៗប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងមានចំពោះម៉ាកសញ្ញានិមួយៗនៅក្នុងក្រុមម៉ាកសញ្ញា សំរាប់រាល់ទំហំ និងប្រភេទនៃកញ្ចប់។

២២. ភាគីទាំងឡាយ គួរគិតគូរដល់ការបង្កើតបំរាមសុខភាព និងសារឱ្យបានមួយ ឬពីរឈុត ដែលប្រើសំរាប់ការចេញជាលើកដំបូង និងសំរាប់ការដាក់ឆ្លាស់គ្នា បន្ទាប់ពីរយៈពេលមួយជាក់លាក់ ដូចជារៀងរាល់ ១២-៣៦ ខែ។ ក្នុងដំណាក់កាលអន្តរកាល ពេលដែលបំរាមសុខភាព និងសារចាស់កំពុងត្រូវបានដាក់ជំនួសដោយបំរាមសុខភាព និងសារមួយឈុតថ្មី ភាគីទាំងឡាយ គួរផ្តល់នូវពេលវេលាមួយដំណាក់មួងៗក្នុងការដាក់ឆ្លាស់គ្នា រវាងឈុតនៃបំរាមសុខភាព និងសារទាំងឡាយ ដែលក្នុងអំឡុងពេលនោះបំរាមសុខភាព និងសារទាំងពីរឈុតត្រូវបានគេយកមកប្រើជាមួយគ្នា។

## សមាសភាពនៃសារ

២៣. ការប្រើបំរាមសុខភាព និងសារច្រើន បង្កើននូវឥទ្ធិពលនៃបំរាមសុខភាព និងសារទាំងនោះ ដោយសារបំរាមសុខភាព និងសារផ្សេងៗពីគ្នា ផ្តល់ការយល់ដឹងដល់មនុស្សផ្សេងៗគ្នា។ បំរាមសុខភាព និងសារ គួរតែលើកឡើងពីបញ្ហាផ្សេងៗគ្នា ទាក់ទងទៅនឹងការប្រើប្រាស់ថ្នាំជក់ ជាបន្ថែមទៅលើផលប៉ះពាល់ដ៏គ្រោះថ្នាក់ដល់សុខភាព និងឥទ្ធិពលនៃការរងផ្សែងថ្នាំជក់ ដូចជា :

- ដំបូន្មានក្នុងការផ្តាច់
- សភាពនៃការញៀនរបស់ថ្នាំជក់
- ផលប៉ះពាល់អវិជ្ជមានលើសេដ្ឋកិច្ច និងសង្គម (ឧទាហរណ៍ ការចំណាយប្រចាំឆ្នាំទៅលើការទិញថ្នាំជក់) និង
- ឥទ្ធិពលនៃការប្រើប្រាស់ថ្នាំជក់ទៅលើមនុស្សសំខាន់ដទៃទៀត (ឧទាហរណ៍ ជម្ងឺ និងការស្លាប់មុនអាយុកាល នៃឪពុកដែលបណ្តាលមកពីការជក់បារី និងអ្នកជាទីស្រឡាញ់ដោយសាររងផ្សែងថ្នាំជក់)។

២៤. ភាគីទាំងឡាយក៏គួរតែគិតពិចារណាផងដែរ ការរិះរកសមាសធាតុថ្មីនៃបំរាមសុខភាព និងសារ ដូចជាផលប៉ះពាល់ដល់បរិស្ថាន និងប្រតិបត្តិការរបស់ឧស្សាហកម្មថ្នាំជក់។

២៥. វាជាការសំខាន់ណាស់ដែលត្រូវបង្ហាញឱ្យគេយល់ពីបំរាមសុខភាព និងសារក្នុងមធ្យោបាយមានប្រសិទ្ធភាព រីឯរបៀបក្នុងការសរសេរសារនោះ គួរមានលក្ខណៈជាអំណាចអាជ្ញា និងជាការផ្តល់ព័ត៌មាន ប៉ុន្តែដោយមិនធ្វើការវិនិច្ឆ័យ។ បំរាមសុខភាព និងសារ គួរតែបង្ហាញឡើងជាភាសាសាមញ្ញ ច្បាស់លាស់ ខ្លី ដែលសមស្រប

ទៅតាមវប្បធម៌។ បំរាមសុខភាព និងសារអាចបង្ហាញឡើងជាច្រើនទម្រង់ ដូចជាព័ត៌មានដែលមានលក្ខណៈបន្ទាល់ វិជ្ជមាន និងគាំទ្រ។

២៦. ភស្តុតាងណែនាំថា បំរាមសុខភាព និងសារ នឹងកាន់តែមានប្រសិទ្ធភាព ប្រសិនបើវាដកស្រង់ចេញពីការផ្សារភ្ជាប់ការប្រើប្រាស់ថ្នាំជក់ទៅនឹងការរន្ធត់ចិត្ត និងនៅពេលដែលព័ត៌មាននោះមានតួអង្គជាមនុស្សពិត ដើម្បីធ្វើឱ្យបំរាមសុខភាព និងសារកាន់តែគួរឱ្យជឿជាក់ ហើយទាក់ទងទៅនឹងមនុស្ស។ បំរាមសុខភាព និងសារដែលនាំឱ្យមានការរំជួលចិត្តជាអវិជ្ជមាន ដូចជាការភ័យខ្លាចជាដើម អាចមានប្រសិទ្ធភាព ជាពិសេសនៅពេលដែលគេរួមបញ្ចូល នូវព័ត៌មានដែលគេធ្វើឡើងដើម្បីបង្កើនហេតុផល និងភាពជឿជាក់ដល់អ្នកជក់បារីឱ្យឈប់ជក់។

២៧. បញ្ញត្តិនៃដំបូន្មានលើការឈប់ជក់បារី និងប្រភពជាក់លាក់សំរាប់ជួយឱ្យឈប់ជក់ លើការវេចខ្ចប់ផលិតផលថ្នាំជក់ដូចជា អស័យដ្ឋានគេហទំព័រ ឬលេខទូរស័ព្ទមិនគិតប្រាក់ "ផ្តល់ប្រឹក្សាពីការឈប់ជក់ បារីតាមទូរស័ព្ទ" អាចមានសារសំខាន់ក្នុងការជួយដល់អ្នកប្រើប្រាស់ថ្នាំជក់ ក្នុងការផ្លាស់ប្តូរឥរិយាបទរបស់ពួកគេ។ ភាគីទាំងឡាយគួរដឹងថា តម្រូវការសេវាកម្មទាក់ទងទៅនឹងការឈប់ជក់បារី អាចទាមទារឱ្យមានធនធានបន្ថែមទៀត។

## ភាសា

២៨. មាត្រា ១១.៣ នៃអនុសញ្ញា ចែងថា ភាគីនិមួយៗត្រូវទាមទារឱ្យមានបំរាមសុខភាព និងព័ត៌មានជាអក្សរដែលបានចែងក្នុងមាត្រា ១១.១(ខ)និងមាត្រា ១១.២ ត្រូវបិទនៅលើកញ្ចប់បារីនិមួយៗ និងកញ្ចប់ផលិតផលថ្នាំជក់ ក៏ដូចជាការវេចខ្ចប់ពីក្រៅ និងការបិទផ្លាកផលិតផលបែបនេះ ជាភាសាសំខាន់មួយ ឬច្រើនរបស់ភាគីនោះ។

២៩. នៅក្នុងប្រទេសដែលមានភាសារសំខាន់លើសពីមួយ បំរាមសុខភាព និងសារអាចដាក់នៅលើផ្ទៃសំខាន់លើសពីមួយភាសា ឬដាក់ឆ្លាស់គ្នា ភាសាផ្សេងគ្នាអាចដាក់នៅលើផ្ទៃសំខាន់ផ្សេងគ្នា។ នៅពេលដែលសមស្រប ភាសាផ្សេងគ្នា ឬភាសាច្រើនរួមបញ្ចូលក៏អាចប្រើបាន ក្នុងតំបន់ផ្សេងគ្នានៃប្រទេសមួយ។

## ការកំណត់ប្រភព

៣០. សេចក្តីថ្លែងការណ៍ពីការកំណត់ប្រភព ផ្តល់នូវប្រភពនៃបំរាមសុខភាព និងសារលើការវេចខ្ចប់ផលិតផលថ្នាំជក់។ ទោះបីជាយ៉ាងណាក៏ដោយ មានមតិជាច្រើនលើកឡើងថា តើប្រភពគួរតែជាផ្នែកមួយនៃបំរាមសុខភាព និងសារ ឬយ៉ាងណា។ ប្រទេសមួយចំនួន ផ្តល់នូវសេចក្តីថ្លែងការណ៍កំណត់ប្រភព ដើម្បីបង្កើនភាពជឿជាក់នៃបំរាមសុខភាព និងសារ ប៉ុន្តែប្រទេសខ្លះទៀតបានសំរេចមិនដាក់បញ្ចូលនូវការកំណត់ប្រភពទេ ដោយមានការព្រួយបារម្ភថា វាអាចធ្វើឱ្យឱនថយចុះនូវប្រសិទ្ធិភាពនៃបំរាមសុខភាព និងសារ។ នៅពេល

ដែលគេតម្រូវឱ្យមានការកំណត់ប្រភព ប្រភពនោះតែងតែត្រូវគេដាក់នៅចុងបញ្ចប់នៃបំរាមសុខភាព ជាទំហំអក្សរតូចជាងបំរាមសុខភាព។ ជាការស្របច្បាប់ ឱកាសជាក់លាក់របស់ភាគីដូចជា ជំនឿ និងឥរិយាបទទាំងឡាយក្នុងចំណោមអនុក្រុមគោលដៅ នឹងកំណត់ថា តើការប្រើប្រាស់ការកំណត់ប្រភព អាចនឹងបង្កើនភាពជឿជាក់ ឬកាត់បន្ថយឥទ្ធិពលនោះ។

៣១. ប្រសិនបើគេតម្រូវឱ្យមាន សេចក្តីថ្លែងការណ៍ពីការកំណត់ប្រភព គួរបញ្ជាក់ឱ្យច្បាស់ពីប្រភពដែលគួរឱ្យ ទុកចិត្តបាន និងឯកទេស ដូចជាអាជ្ញាធរសុខាភិបាលជាតិ។ សេចក្តីថ្លែងការណ៍ គួរតែតូចល្មមដែលមិនអាចធ្វើឱ្យឱនថយដល់ការសំគាល់ជាទូទៅ និងឥទ្ធិពលនៃសារ ប៉ុន្តែវាគួរតែធំល្មមនឹងអាចមើលឃើញ។

## ព័ត៌មានស្តីពីសមាសធាតុ និងការបញ្ចេញ (ផ្សែង) របស់ថ្នាំជក់

៣២. មាត្រា ១១.២ នៃអនុសញ្ញា ចែងថា ដុំ ឬកញ្ចប់និមួយៗនៃផលិតផលថ្នាំជក់ និងប្រដាប់វេចខ្ចប់ និងផ្លាកខាងក្រៅរបស់ផលិតផលនោះ ត្រូវបន្ថែមបំរាមសុខភាព ដែលមានចែងនៅក្នុងមាត្រា ១១.១(ខ) ត្រូវមានព័ត៌មានស្តីពីសមាសធាតុពាក់ព័ន្ធ និងការបញ្ចេញ(ផ្សែង)របស់ផលិតផលថ្នាំជក់ដូចមានការឱ្យ និយមន័យដោយអាជ្ញាធរជាតិ។

៣៣. ក្នុងការអនុវត្តន៏កាតព្វកិច្ចនេះ ភាគីទាំងឡាយគួរទាមទារឱ្យមានសេចក្តីថ្លែងការណ៍ជាគុណភាពដែលពាក់ព័ន្ធ ដាក់បង្ហាញនៅលើដុំ ឬកញ្ចប់និមួយៗស្តីអំពីការបញ្ចេញ (ផ្សែង) របស់ផលិតផលថ្នាំជក់។ ឧទាហរណ៍នៃសេចក្តីថ្លែងការណ៍នេះរួមមាន "ផ្សែងដែលចេញពីបារីផ្ទុកទៅដោយជាតិបង់ហ្សែន ដែលគេស្គាល់ថា ជាសារធាតុបង្កជម្ងឺមហារីក" និង "ផ្សែងបារីធ្វើឱ្យអ្នករងនូវសារធាតុគីមីបង្កជម្ងឺមហារីកជាង ៦០ ប្រភេទ"។ ភាគីទាំងឡាយ គួរទាមទារឱ្យមានផងដែរ នូវការបង្ហាញព័ត៌មាននេះ នៅលើផ្ទៃសំខាន់ ឬនៅលើផ្នែកខ្លះនៃផ្ទៃសំខាន់ ឬនៅលើផ្ទៃផ្សេងទៀត ដែលមិនគ្របដណ្តប់ដោយមានបំរាមសុខភាព និងសារ។

៣៤. ភាគីទាំងឡាយមិនគួរទាមទារនូវសេចក្តីថ្លែងជាគុណភាព ឬជាបរិមាណក្តីនៅលើការវេចខ្ចប់ និងការបិទផ្លាកស្តីពីសមាសធាតុ និងការបញ្ចេញ (ផ្សែង) ដែលប្រហែលជាអាចនាំឱ្យមានការយល់ថា ម៉ាកសញ្ញាណាមួយមានគ្រោះថ្នាក់តិចជាងម៉ាកសញ្ញាណាផ្សេងទៀត ដូចជាជាតិជ័រថារ នីកូទីន និងជាតិកាបូនម៉ូណូអុកស៊ីត ឬសេចក្តីថ្លែងថា "បារីនេះមានសារធាតុ នីត្រូសាមីនក៏រិតទាប" ឡើយ ។

៣៥. ល្បះទាំងបីខាងលើគួតែអានជាមួយគ្នានឹងល្បះទី ៤៣-៤៥ ។

## ដំណើរការក្នុងការបង្កើតការទាមទារឱ្យមានការវេចខ្ចប់ និងការបិទផ្លាកប្រកបដោយប្រសិទ្ធភាព ការគិតពិចារណាទៅលើប្រភេទនៃផលិតផល

៣៦. មាត្រា ១១.១(ខ) នៃអនុសញ្ញា តម្រូវឱ្យភាគីនិមួយៗបង្កើត និងអនុវត្តវិធានការដ៏មានប្រសិទ្ធភាព ដើម្បីធានាថា ដុំ ឬកញ្ចប់និមួយៗនៃផលិតផលថ្នាំជក់ និងប្រដាប់វេចខ្ចប់ ឬផ្លាកខាងក្រៅនៃផលិតផលនោះ មាន

ដាក់បំរាមសុខភាព និងសារ។ មិនគួរឱ្យមានការលើកលែងចំពោះក្រុមហ៊ុនខ្នាតតូច ម៉ាកសញ្ញា ឬប្រភេទផ្សេងទៀត នៃថ្នាំជក់ឡើយ។ ភាគីទាំងឡាយ គួរពិចារណាទៅលើការទាមទារឱ្យមានបំរាមសុខភាព និងសារផ្សេងគ្នា លើផលិតផលថ្នាំជក់ផ្សេងគ្នាដូចជា បារី ស៊ីហ្គា ថ្នាំចុក ថ្នាំជក់ខ្សៀរ ស្លឹកថ្នាំជក់មូរ និងថ្នាំជក់ខ្សៀរទឹក ដើម្បីឱ្យមានការផ្តោតជាក់លាក់ទៅលើផលប៉ះពាល់នៃផលិតផលនិមួយៗ។

## ប្រភេទផ្សេងៗនៃការវេចខ្ចប់

៣៧. ភាគីទាំងឡាយ គួរមានការយល់ដឹងទូលំទូលាយអំពីប្រភេទផ្សេងគ្នា នៃការវេចខ្ចប់ផលិតផលថ្នាំជក់ ដែលរកឃើញក្នុងប្រទេសរបស់ខ្លួន និងគួរតែកំណត់ពីរបៀបដែលបំរាម និងសារដែលបានស្នើឡើងនេះនឹងអនុវត្តចំពោះទ្រង់ទ្រាយ និងប្រភេទនៃការវេចខ្ចប់ ដូចជា កំប៉ុង ប្រអប់រុញ និងប្រអប់គ្រុំ សុង កញ្ចប់ថ្លា ឬកញ្ចប់ដែលមានផលិតផលមួយដុំ។

## អនុក្រុមប្រជាពលរដ្ឋគោលដៅ

៣៨. ភាគីទាំងឡាយ គួរពិចារណាទៅលើការរចនាបំរាមសុខភាព ដែលផ្តោតគោលដៅទៅលើអនុក្រុម ដូចជាយុវវ័យ និងកែប្រែបំរាមសុខភាពឱ្យបានច្រើន និងភាពឆ្លាស់គ្នារបស់វាឱ្យបានស្របទៅតាមគ្នា។

## ការសាកល្បងទីផ្សារជាមុន

៣៩. ដោយផ្អែកទៅតាមធនធាននិងពេលវេលាដែលមាន ភាគីទាំងឡាយគួរពិចារណាទៅលើការសាកល្បងទីផ្សារជាមុន ដើម្បីវាយតម្លៃពីប្រសិទ្ធភាពនៃបំរាមសុខភាព និងសារលើប្រជាពលរដ្ឋគោលដៅដែលបានគិតទុក។ ការសាកល្បងទីផ្សារជាមុន អាចនាំឱ្យមានការកំណត់តទិ្ធពលដែលមិនបានព្រៀងទុកជាមុន ដូចជាការកើនឡើងដោយអចេនានូវចំណង់ជក់បារីខ្លាំង និងការវាយតម្លៃពីភាពត្រឹមត្រូវតាមលក្ខណៈវប្បធម៌។ គួរពិចារណាលើការអញ្ជើញសង្គមស៊ីវិល ដែលមិនពាក់ព័ន្ធជាមួយនឹងឧស្សាហកម្មថ្នាំជក់ ដើម្បីរួមចំណែកក្នុងដំណើការនេះ។ ជាលទ្ធផលចុងក្រោយ ការសាកល្បងទីផ្សារជាមុនអាចចំណាយតិចជាងការផ្លាស់ប្តូរវិធានការស្របច្បាប់ នៅដំណាក់កាលបន្ទាប់ ។

៤០. ភាគីទាំងឡាយ គួរសំគាល់ថា ការសាកល្បងទីផ្សារជាមុនមិនត្រូវការពេលវេលាយូរ មិនសាំញ៉ាំ ហើយក៏មិនថ្លៃដែរ។ ព័ត៌មានដ៏មានតម្លៃអាចទទួលបានពីក្រុមគោលដៅសាមញ្ញនៃប្រជាពលរដ្ឋគោលដៅ ឬព័ត៌មានដែលបានមកពីការពិគ្រោះយោបល់ដោយផ្អែកលើអ៊ិនធឺណេត អាចជាជំរើសដែលលឿន និងមានតម្លៃថោកមួយ។ ការសាកល្បងទីផ្សារជាមុន អាចធ្វើឡើងស្របគ្នាជាមួយនឹងការធ្វើសេចក្តីព្រាងវិធានការស្របច្បាប់ ដើម្បីជៀសវាងការពន្យារពេលហួសហេតុពេកក្នុងការអនុវត្តន៍។

**ព័ត៌មាន និងការចូលរួមជាសាធារណៈ**

៤១. ភាគីទាំងឡាយ គួរផ្តល់ព័ត៌មានដល់សាធារណៈជន ពីសំណើក្នុងការចាប់ផ្តើមអនុវត្តនូវបំរាមសុខភាព និងសារថ្មី។ ការគាំទ្រជាសាធារណៈ នឹងជួយភាគីទាំងឡាយក្នុងការណែនាំបំរាមសុខភាព និងសារថ្មី។ ទោះបីជាយ៉ាងណា ភាគីទាំងឡាយគួរតែធានាថា ការផ្តល់ព័ត៌មាន និងការចូលរួមជាសាធារណៈ មិនពន្យារពេលជ្រុលហួសហេតុពេកទេ ដល់ការអនុវត្តន៍អនុសញ្ញា។

**ការគាំទ្រដល់សកម្មភាពទំនាក់ទំនង**

៤២. ការចាប់ផ្តើមអនុវត្តនូវបំរាមសុខភាព និងសារថ្មី កាន់តែមានប្រសិទ្ធភាព នៅពេលដែលវាសម្របសម្រួលជាមួយនឹងការផ្តល់ព័ត៌មានជាសាធារណៈដែលមាននិរន្តរភាព និងយុទ្ធនាការអប់រំប្រកបដោយវិសាលភាព។ ព័ត៌មានទាន់ហេតុការណ៍ គួរតែផ្តល់ឱ្យដល់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ការគ្របដណ្តប់នៃប្រព័ន្ធផ្សព្វផ្សាយ អាចបង្កើននូវឥទ្ធិពលអប់រំនៃបំរាមសុខភាព និងសារថ្មី។

## បង្កើតការរឹតបន្តឹងលើ ការវេចខ្ចប់ និងការបិទផ្លាក ប្រកបដោយប្រសិទ្ធភាព

**បង្ការនូវការវេចខ្ចប់ និងការបិទផ្លាកផ្តល់ព័ត៌មានដែលនាំឱ្យយល់ខុស ឬដែលឆបោក**

៤៣. មាត្រា ១១.១(ក)នៃអនុសញ្ញា ចែងថា ភាគីទាំងឡាយត្រូវអនុម័ត និងអនុវត្ត ស្របតាមច្បាប់ជាតិរបស់ខ្លួន នូវវិធានការដ៏មានប្រសិទ្ធភាព ដើម្បីធានាថា ការវេចខ្ចប់ និងការបិទផ្លាកផលិតផលថ្នាំជក់ ពុំមែនផ្សព្វផ្សាយដើម្បីលក់ផលិតផលថ្នាំជក់ ដោយមធ្យោបាយដែលមិនពិត នាំឱ្យយល់ខុស ដែលឆបោក ឬហាក់ដូចជាបង្កើតឱ្យមានអារម្មណ៍ ដែលមានការភាន់ច្រឡំចំពោះលក្ខណៈរបស់វា ផលប៉ះពាល់ដល់សុខភាព គ្រោះថ្នាក់ការបញ្ចេញ(ផ្សែង)រាប់បញ្ចូលទាំងការពិពណ៌នា សញ្ញាពាណិជ្ជកម្ម អត្តបដិរូប ឬសញ្ញាដទៃទៀតណា ដែលបង្កើតនូវអារម្មណ៍មិនពិត ដោយផ្ទាល់ ឬដោយប្រយោលថា ផលិតផលថ្នាំជក់ជាពិសេសមួយ មានគ្រោះថ្នាក់តិចជាងផលិតផលថ្នាំជក់ដទៃទៀត នេះអាចរាប់បញ្ចូលនូវពាក្យដូចជា "មានជ័រតិច" "ស្រាល" "ស្រាលបំផុត" ឬ "មិនខ្លាំង" ដែលតារាងនេះត្រូវបានគេចង្អុលបង្ហាញ ប៉ុន្តែមិនទូលំទូលាយទេ។ ក្នុងការអនុវត្តន៍កាតព្វកិច្ចដោយអនុលោមតាមមាត្រា ១១.១(ក) ភាគីទាំងឡាយមិនត្រឹមតែត្រូវបានទាមទារឱ្យហាមឃាត់ពាក្យជាក់លាក់ទាំងនេះប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងគួរហាមឃាត់ពាក្យ "អស្ចារ្យ" "ច្រើនបំផុត" និងពាក្យប្រហាក់ប្រហែលគ្នាជាភាសាណាមួយ ដែលអាចនាំឱ្យអ្នកប្រើប្រាស់យល់ខុស។

៤៤. ភាគីទាំងឡាយ គួរហាមឃាត់ការដាក់បង្ហាញនូវអត្តបដិរូប សំរាប់ផលនៃការបញ្ចេញ (ផ្សែង) ដូចជាជាតិជ័រ នីកូទីន និងកាបូនម៉ូណូអុកស៊ីត លើការវេចខ្ចប់ និងបិទផ្លាកដោយរាប់បញ្ចូល ទាំងពេលដែលគេប្រើជាផ្នែកមួយនៃយីហោ សញ្ញាពាណិជ្ជកម្ម ។ ជាតិជ័រ នីកូទីន និងការបញ្ចេញផ្សែងដទៃទៀតដែលទាញយកចេញមកពីម៉ាស៊ីនសាកល្បង មិនផ្តល់នូវការប៉ាន់ប្រមាណជាសក្តានុពលនៃផលប៉ះពាល់ដល់មនុស្សឡើយ។

លើសពីនេះទៀត គ្មានភស្តុតាងសន្និដ្ឋានផ្នែកសិក្សារោគរាតត្បាត និងផ្នែកវិទ្យាសាស្ត្រណាមួយដែលថា បារីដែលមានផ្សែងតិច វាស់ដោយម៉ាស៊ីន នាំមកនូវគ្រោះថ្នាក់តិចជាងបារីដែលបញ្ចេញផ្សែងច្រើនឡើយ ។ ការស្វែងរកទីផ្សាររបស់បារី ដែលគេអះអាងថាមានជាតិជ័រ និងជាតិនីកូទីនតិចនោះ នាំឱ្យមានការយល់ខុសថា បារីទាំងនេះមានគ្រោះថ្នាក់តិច ។

៤៥. ភាគីទាំងឡាយ គួរបង្ការការដាក់បង្ហាញនូវកាលបរិច្ឆេទផុតកំណត់លើការវេចខ្ចប់ និងការបិទផ្លាកផលិតផលថ្នាំជក់ ដែលនាំឱ្យមានការយល់ខុស បញ្ឆោតអ្នកប្រើប្រាស់ឱ្យសន្និដ្ឋានថា ថ្នាំជក់មានសុវត្ថិភាពក្នុងការប្រើប្រាស់ នៅពេលវេលាណាមួយ ។

## ការវេចខ្ចប់ដែលគ្មានកញ្ចប់លាត

៤៦. ភាគីទាំងឡាយ គួរពិចារណាពីវិធានការដែលរឹតបន្តឹង និងហាមឃាត់ការប្រើប្រាស់នូវរូបភាពយីហោ ឬព័ត៌មានផ្សព្វផ្សាយដើម្បីលក់ ដោយមាននិមិត្តសញ្ញា ពណ៌ធម្មជាតិ លើការវេចខ្ចប់ជាជាងម៉ាកយីហោ និងឈ្មោះផលិតផលដែលដាក់បង្ហាញជាពណ៌បទដ្ឋាន និងទម្រង់រចនាបទអក្សរ (ការវេចខ្ចប់ដោយកញ្ចប់លាត) ។ ការនេះអាចបង្កើនការកត់សំគាល់ និងប្រសិទ្ធភាពនៃបំរាមសុខភាព និងសារ ដែលការពារកញ្ចប់ពីការបង្វែរចំណាប់អារម្មណ៍ពីសារទាំងនេះ ហើយបង្ហាញពីបច្ចេកទេសនៃការរចនាកញ្ចប់ដែលអាចលើកឡើងថា ផលិតផលខ្លះមានសុវត្ថិភាពជាងផលិតផលខ្លះទៀត ។

# វិធានការច្បាប់

## ការធ្វើសេចក្តីព្រាង

៤៧. ក្នុងការធ្វើសេចក្តីព្រាងពីវិធានការដែលពាក់ព័ន្ធទៅនឹងការវេចខ្ចប់ និងការបិទផ្លាកផលិតផលថ្នាំជក់ ភាគីទាំងឡាយ គួរចាត់ទុកបញ្ហាទាំងឡាយដូចជា អ្នកដែលនឹងទទួលខុសត្រូវចំពោះរដ្ឋបាលរបស់ពួកគេ វិធីសាស្ត្រដែលអាចមានដើម្បីធានាដល់ការគោរពតាម និងការពង្រឹង ហើយនិងក៏រិត ឬក៏រិតទាំងឡាយដែលរដ្ឋាភិបាលពាក់ព័ន្ធ ។

## ការគ្រប់គ្រង

៤៨. ភាគីទាំងឡាយ គួរកំណត់អាជ្ញាធរមួយ ឬច្រើន ដែលទទួលខុសត្រូវចំពោះការត្រួតពិនិត្យមើលការអនុវត្តន៍នៃវិធានការវេចខ្ចប់ និងបិទផ្លាកផលិតផលថ្នាំជក់ ។ ភាគីទាំងឡាយ គួរពិចារណាដើម្បីធានាថា អាជ្ញាធរពាក់ព័ន្ធដែលទទួលខុសត្រូវចំពោះការត្រួតពិនិត្យថ្នាំជក់ គឺជាអ្នកគ្រប់គ្រងរដ្ឋបាលនៃវិធានការច្បាប់ទាំងនេះ ។ ក្នុងករណីដែលការទទួលខុសត្រូវ ត្រូវបានប្រគល់ឱ្យស្ថាប័នផ្សេងមួយទៀតរបស់រដ្ឋាភិបាល នោះ

អាជ្ញាធរសុខាភិបាលដែលពាក់ព័ន្ធ គួរជាអ្នកផ្តល់ព័ត៌មានអំពីភាពជាក់ច្បាស់សំរាប់ការដាក់ផ្លាក ដល់ស្ថាប័ននោះ។

**ការកំណត់ទំហំ**

៤៩. ភាគីទាំងឡាយ គួរធានាថា បញ្ញត្តិនៃការវេចខ្ចប់ និងការបិទផ្លាក ដែលទាក់ទងទៅនឹងមាត្រា១១ នៃអនុសញ្ញានេះ អនុវត្តស្មើៗគ្នាចំពោះរាល់ផលិតផលថ្នាំជក់ដែលលក់ដូរនៅក្នុងប្រទេស និងធានាថា គ្មានការលើកលែងណាមួយត្រូវបានធ្វើឡើងរវាងផលិតផលដែលផលិតក្នុងស្រុក នាំចូល និងបំរុងទុកសំរាប់ការលក់ដោយអនុគ្រោះពន្ធ នៅក្នុងប្រទេសរបស់ភាគី។ ភាគីទាំងឡាយ គួរពិចារណាពីកាលៈទេសៈទាំងឡាយណា ដែលវិធានការទាំងនេះ នឹងត្រូវបានយកមកអនុវត្តចំពោះផលិតផលនាំចេញ។

**ការចំណាយ**

៥០. ភាគីទាំងឡាយគួរធានាថា ការចំណាយទៅលើការដាក់បំរាមសុខភាព និងសារក៏ដូចជាព័ត៌មានស្តីពីសមាសធាតុ និងការបញ្ចេញ (ផ្សែង) លើការវេចខ្ចប់ផលិតផលថ្នាំជក់ជាបន្ទុករបស់ឧស្សាហកម្មថ្នាំជក់។

**ការទទួលខុសត្រូវ**

៥១. ស្របជាមួយនឹងមាត្រា១៩ នៃអនុសញ្ញា ភាគីទាំងឡាយគួរពិចារណាលើការរាប់បញ្ចូលបញ្ញត្តិទាំងឡាយក្នុងការធ្វើឱ្យច្បាស់លាស់ថា ការទាមទារឱ្យដាក់បំរាមសុខភាព ឬសារ ឬដាក់បង្ហាញព័ត៌មានស្តីពីផលិតផលថ្នាំជក់ មិនដកចេញ ឬកាត់បន្ថយនូវកាតព្វកិច្ចរបស់ឧស្សាហកម្មថ្នាំជក់ ដោយរាប់បញ្ចូល ប៉ុន្តែមិនកំណត់ចំពោះ កាតព្វកិច្ចក្នុងការព្រមានដល់អ្នកប្រើប្រាស់ អំពីគ្រោះថ្នាក់ដល់សុខភាពបណ្តាលមកពីការប្រើប្រាស់ថ្នាំជក់ និងការរងផ្សែងថ្នាំជក់ ។

**បញ្ញត្តិជាក់លាក់**

៥២. ភាគីទាំងឡាយត្រូវធានាថា ភាពជាក់លាក់ដែលច្បាស់ និងលំអិត ត្រូវបានផ្តល់ឱ្យនៅក្នុងវិធានការច្បាប់ដើម្បីកាត់បន្ថយឱកាស សំរាប់អ្នកផលិត និងអ្នកនាំចេញផលិតផលថ្នាំជក់ ដើម្បីងាកទៅរកការអនុវត្តន៍បំរាមសុខភាព និងសារ ព្រមទាំងដើម្បីការពារភាពមិនស៊ីសង្វាក់គ្នាក្នុងចំណោមផលិតផលថ្នាំជក់។ ក្នុងការធ្វើសេចក្តីព្រាងវិធានការទាំងនេះ ភាគីទាំងឡាយ គួរតែត្រួតពិនិត្យឡើងវិញ នូវបញ្ជីខាងក្រោមៈ

ការវេចខ្ចប់ និងផលិតផល (សូមមើលទៅល្បះទី ៣៧)

ភាសាសំរាប់ប្រើប្រាស់នៅក្នុងអត្ថបទដែលគេអនុញ្ញាតនៃបំរាមសុខភាព និងសារ និងនៅក្នុងព័ត៌មានស្តីពីសមាសធាតុ និងការបញ្ចេញ(ផ្សែង) លើការវេចខ្ចប់ ដោយរួមបញ្ចូលទាំងរបៀបដែលត្រូវដាក់ភាសា ប្រសិនបើមានភាសាលើសពីមួយ

ការអនុវត្តនីភាពឆ្លាស់គ្នា និងការកំណត់ពេលវេលា រួមទាំងចំនួននៃបំរាមសុខភាព និងសារ ដើម្បីឱ្យវាមានដំណាលគ្នា ព្រមទាំងភាពជាក់លាក់នៃរយៈពេលអន្តរកាល និងកាលកំណត់ដែលនៅក្នុងចន្លោះពេលនោះ បំរាមសុខភាព និងសារថ្មីត្រូវតែមាន

ការអនុវត្តនីការចែកចាយ ដើម្បីទទួលបាននូវការដាក់បង្ហាញស្មើៗគ្នានូវបំរាមសុខភាព និងសារ លើកញ្ចប់សំរាប់លក់រាយ មិនមែនត្រឹមតែសំរាប់ក្រុមម៉ាកយីហោនិមួយៗប៉ុណ្ណោះទេ តែវាថែមទាំងសំរាប់ម៉ាកយីហោ និមួយៗនៅក្នុងក្រុមម៉ាកយីហោ សំរាប់គ្រប់ទំហំ និងប្រភេទកញ្ចប់

របៀបដែលអក្សរ រូបភាព អត្ថបដិរូប នៃបំរាមសុខភាព និងសារ គួរមាននៅលើការវេចខ្ចប់ (រាប់បញ្ចូលទាំងភាពជាក់លាក់នៃទីតាំង ពាក្យ ទំហំ ពណ៌ ទម្រង់អក្សរ ការតម្រៀប គុណភាពនៃការបោះពុម្ពជាដើម) រួមទាំងព័ត៌មានដាក់បញ្ចូលខាងក្នុង ព័ត៌មានខាងក្រៅ និងនៅលើផ្ទៃកញ្ចប់ផងដែរ

ប្រភេទផ្សេងគ្នានៃបំរាមសុខភាព និងសារ សំរាប់ប្រភេទផ្សេងគ្នានៃផលិតផលថ្នាំជក់ដែលសមស្រប

ការកំណត់ប្រភព ប្រសិនបើអាច ដោយរាប់បញ្ចូលទាំងការដាក់អក្សរ និងទម្រង់អក្សរ (ភាពជាក់លាក់ដែលលំអិតចំពោះបំរាមសុខភាព និងសារខ្លួនឯង) និង

ការហាមឃាត់ការផ្សព្វផ្សាយដើម្បីលក់ដោយមធ្យោបាយដែលមិនពិត នាំឱ្យយល់ខុស បោកបញ្ឆោត ឬហាក់ដូចជាបង្កើតនូវអារម្មណ៍មិនពិត ដោយអនុលោមតាមមាត្រា ១១.១(ក) នៃអនុសញ្ញា។

**ឯកសារប្រភព**

៥៣. ភាគីទាំងឡាយ គួរពិចារណាដល់ការផ្តល់នូវ "ឯកសារប្រភព" ដែលជាគំរូដែលអាចមើលឃើញច្បាស់ទាំងឡាយ នៃរបៀបដែលបំរាមសុខភាព និងសារ ហើយនិងព័ត៌មានផ្សេងទៀតត្រូវមាននៅលើការវេចខ្ចប់។ ឯកសារប្រភពមានប្រយោជន៍ជាពិសេស នៅក្នុងករណីដែល ភាសាប្រើប្រាស់នៅក្នុងវិធានការច្បាប់ មិនច្បាស់គ្រប់គ្រាន់។

**ផ្លាក ឬគម្របដែលបិទបន្ថែម**

៥៤. ភាគីទាំងឡាយ គួរធានាថា ផ្លាក ស្ទីយ័រ កេស គម្រប ឆ្នុក កញ្ចប់ និងផ្លាកសំរាប់ផ្សព្វផ្សាយលក់ខាងក្នុង និងខាងក្រៅ មិនធ្វើឱ្យបំរាមសុខភាព និងសារទៅជាស្រអាប់ រលុប ឬខូចខាតឡើយ។ ឧទាហរណ៍ ការបិទផ្លាកបន្ថែមអាចត្រូវបានអនុញ្ញាត តែក្នុងករណីដែលផ្លាកនេះមិនអាចដកចេញ និងប្រើចំពោះតែប្រដាប់សំរាប់ផ្ទុក ជាលោហៈធាតុ ឬឈើ សំរាប់ដាក់ផលិតផលផ្សេងពីថ្នាំជក់ប៉ុណ្ណោះ។

## ការទទួលខុសត្រូវចំពោះមុខច្បាប់សំរាប់ការគោរពតាម

៥៥. ភាគីទាំងឡាយ គួរកំណត់ឱ្យជាក់លាក់ថា រាល់អ្នកផលិត អ្នកនាំចូល កន្លែងលក់ដុំ និងលក់រាយផលិតផលថ្នាំជក់ មានការទទួលខុសត្រូវចំពោះមុខច្បាប់ សំរាប់ការគោរពតាមវិធានការវេចខ្ចប់ និងបិទផ្លាក។

## ការពិន័យ

៥៦. ដើម្បីរារាំងដល់ការមិនគោរពច្បាប់ ភាគីទាំងឡាយគួរកំណត់ឱ្យបានជាក់លាក់នូវការផាក ឬពិន័យឱ្យស័ក្តិសមទៅនឹងការបំពានដែលមានលក្ខណៈធ្ងន់ធ្ងរ និងករណីល្មើសច្រំដែល ។

៥៧. ភាគីគួរពិចារណាលើការបង្កើត នូវការពិន័យដែលស្របទៅនឹងប្រព័ន្ធច្បាប់ និងវប្បធម៌របស់ភាគី ដែលរួមបញ្ចូលការបង្កើត និងការពង្រឹងបទល្មើស និងការផ្អាក ការកាត់បន្ថយ និងការលុបចោលនូវអាជ្ញាប័ណ្ណជំនួញ និងនាំចូល។

## អំណាចអនុវត្តន៍

៥៨. ភាគីទាំងឡាយ គួរពិចារណាដល់ការផ្តល់អំណាចដល់អាជ្ញាធរប្រតិបត្តិ ក្នុងការបញ្ជាអ្នកប្រព្រឹត្តិល្មើសឱ្យប្រមូលយកផលិតផលថ្នាំជក់ដែលគេមិនគោរពតាមច្បាប់មកវិញ និងសងនូវការខូចខាតដែលកើតចេញពីការប្រមូលយកមកវិញទាំងនេះ ក៏ដូចជាអំណាចក្នុងការដាក់ទណ្ឌកម្មណាមួយ ដែលគេចាត់ទុកថាជាការសមរម្យ ដោយរាប់បញ្ចូលទាំងការរឹបអូស និងការបំផ្លាញនូវផលិតផលថ្នាំជក់ដែលមិនគោរពច្បាប់ទាំងនោះ។ លើសពីនេះទៀត ភាគីទាំងឡាយគួរពិចារណាធ្វើការប្រកាសជាសាធារណៈ ពីឈ្មោះរបស់អ្នកដែលបានប្រព្រឹត្តិល្មើស និងសភាពនៃបទល្មើសរបស់ពួកគេ។

## កាលកំណត់ក្នុងការផ្គត់ផ្គង់

៥៩. ដើម្បីធានាបាននូវការចាប់ផ្តើមអនុវត្តបំរាមសុខភាព និងសារឱ្យបានទាន់ពេលវេលា វិធានការច្បាប់គួរតែកំណត់ឱ្យជាក់លាក់ នូវកាលកំណត់តែមួយ ដែលអ្នកផលិត អ្នកនាំចូល អ្នកលក់ដុំ និងអ្នកលក់រាយ ត្រូវតែផ្គត់ផ្គង់តែផលិតផលថ្នាំជក់ដែលគោរពតាមការទាមទារថ្មីៗទាំងនេះ។ ពេលវេលាកំណត់នេះ ត្រូវលៃឱ្យគ្រប់គ្រាន់ល្មម សំរាប់ឱ្យអ្នកផលិត អ្នកនាំចូល រៀបចំបោះពុម្ពកញ្ចប់ថ្មី។ រយៈពេលមិនលើសពី១២ខែ ចាប់ពីថ្ងៃដែល អនុម័តវិធានការច្បាប់ គួរតែគ្រប់គ្រាន់ក្នុងស្ទើរតែគ្រប់កាលៈទេសៈ។

## ការពិនិត្យឡើងវិញ

៦០. ភាគីទាំងឡាយគួរទទួលស្គាល់ថា ការធ្វើសេចក្តីព្រាងនូវវិធានការច្បាប់ សំរាប់ការវេខ្ចប់ និងការបិទផ្លាកនៃផលិតផលថ្នាំជក់ មិនមែនជាការងារដែលធ្វើបានតែក្នុងមួយពេលនោះទេ។ វិធានការច្បាប់គួតែត្រូវពិនិត្យ

ឡើងវិញជាទៀងទាត់ និងធ្វើឱ្យវាមានភាពទាន់សភាពការណ៍ នៅពេលដែលមានភស្តុតាងថ្មីកើតឡើង និង នៅពេលដែលបំរាមសុខភាព និងសារជាក់លាក់ណាមួយចាស់ពេក មិនអាចប្រើប្រាស់តទៅទៀតបាន។ នៅពេលដែលមានការពិនិត្យឡើងវិញ និងធ្វើឱ្យទាន់សភាពការណ៍ជាទៀងទាត់នោះ ភាគីទាំងឡាយគួរតែពិចារណា លើបទពិសោធន៍ក្នុងការប្រើប្រាស់វិធានការវេចខ្ចប់ និងបិទផ្លាករបស់ខ្លួន បទពិសោធនៅប្រទេសដទៃៗ ព្រមទាំងប្រតិបត្តិរបស់ឧស្សាហកម្មថ្នាំជក់នៅក្នុងវិស័យនេះ។ ការពិនិត្យឡើងវិញ និងការធ្វើឱ្យទាន់សភាពការណ៍ អាចជួយកំណត់ពីចំណុចខ្សោយ និងចន្លោះប្រហោងទាំងឡាយ និងវិស័យលេចធ្លោទាំងឡាយដែលភាសាប្រើប្រាស់នៅក្នុងវិធានការទាំងនេះគួរតែបញ្ជាក់។

## ការប្រតិបត្តិ

### ហេដ្ឋារចនាសម្ព័ន្ធ

៦១. ភាគីទាំងឡាយគួរពិចារណាពីការធានាឱ្យមាន នូវហេដ្ឋារចនាសម្ព័ន្ធដែលចាំបាច់ចំពោះការគោរពតាម និងអនុវត្តសកម្មភាពចាំបាច់។ ភាគីទាំងឡាយក៏គួរតែពិចារណាផងដែរទៅលើការផ្តល់ថវិកា សំរាប់សកម្មភាពទាំងនេះ។

### យុទ្ធសាស្ត្រ

៦២. ដើម្បីលើកកំពស់ការគោរពតាម ភាគីទាំងឡាយគួរផ្តល់ព័តិមានដល់អ្នកដែលពាក់ព័ន្ធ ការទាមទាររបស់ច្បាប់មុននឹងចូលជាធរមាន។ យុទ្ធសាស្ត្រផ្សេងៗគ្នាអាចនឹងតម្រូវឱ្យមាន សំរាប់អ្នកដែលពាក់ព័ន្ធ ដូចជាអ្នកផលិត អ្នកនាំចូល អ្នកលក់ដុំ និងអ្នកលក់រាយ ។

៦៣. ភាគីទាំងឡាយគួរពិចារណា នូវការការប្រើប្រាស់អ្នកត្រួតពិនិត្យ ឬភ្នាក់ងារពង្រឹង ដើម្បីអនុវត្តការត្រួតពិនិត្យដល់កន្លែងជាទៀងទាត់ នូវផលិតផលថ្នាំជក់ នៅកន្លែងផលិត និងនាំចូល ព្រមទាំងនៅតាមកន្លែងលក់ ដើម្បីធានាឱ្យបានថា ការវេចខ្ចប់ និងការបិទផ្លាកធ្វើឡើងដោយគោរពតាមច្បាប់។ វាអាចមិនចាំបាច់ក្នុងការបង្កើតប្រព័ន្ធត្រួតពិនិត្យថ្មី ប្រសិនមានយន្តការត្រួតពិនិត្យទាំងនោះស្រាប់ ដែលអាចពង្រីករហូតដល់ការត្រួតពិនិត្យលើមុខជំនួញទាំងមូលតាមការទាមទារ ។ នៅពេលដែលអាចអនុវត្តបាន អ្នកដែលពាក់ព័ន្ធគួរតែត្រូវបានផ្តល់ព័តិមានដែលថា ផលិតផលថ្នាំជក់នឹងត្រូវទទួលការត្រួតពិនិត្យដល់កន្លែងជាទៀងទាត់នៅកន្លែងលក់។

### ការឆ្លើយតបទៅនឹងការមិនគោរពច្បាប់

៦៤. ភាគីទាំងឡាយគួរធានាថា អាជ្ញាធរពង្រឹងច្បាប់បានត្រៀមខ្លួនរួចជាស្រេច ដើម្បីឆ្លើយតបយ៉ាងឆាប់រហ័ស និងយ៉ាងម៉ឺងម៉ាត់ទៅកាន់ការមិនគោរពច្បាប់។ ការឆ្លើយតបដែលម៉ឺងម៉ាត់ និងទាន់ពេលវេលា ចំពោះករណី

ល្មើសលើកដំបូងៗ នឹងបញ្ជាក់ច្បាស់ថា ការគោរពច្បាប់ត្រូវបានគេរំពឹងទុក ហើយនឹងជួយសម្រួលដល់ការពង្រឹងការអនុវត្តន៍ច្បាប់នាពេលអនាគត។ ភាគីទាំងឡាយ គួរពិចារណាលើការបង្ហាញជាសាធារណៈលទ្ធផលនៃសកម្មភាពពង្រឹងច្បាប់ ដើម្បីផ្ញើសារយ៉ាងម៉ឺងម៉ាត់ថា ការមិនអនុវត្តន៍តាមច្បាប់ នឹងត្រូវបានគេស៊ើបអង្កេត ហើយវិធានការនឹងត្រូវគេចាត់ឡើង។

### បណ្តឹង

៦៥. ភាគីទាំងឡាយគួរពិចារណាលើកទឹកចិត្តសាធារណៈជន ឱ្យរាយការណ៍ពីការបំពាន ដើម្បីលើកកំពស់ការអនុវត្តន៍តាមច្បាប់។ វាអាចជាការចាំបាច់ ក្នុងការបង្កើតកន្លែងទំនាក់ទំនងពង្រឹងការអនុវត្តន៍ច្បាប់ សំរាប់រាយការណ៍ពីករណីនៃការមិនគោរពតាម។ ភាគីទាំងឡាយគួរធានាថា បណ្តឹងទាំងឡាយត្រូវបានស៊ើបអង្កេត និងដោះស្រាយទាន់ពេលវេលា និងដោយហ្មត់ចត់បំផុត។

### ការតាមដាន និងវាយតម្លៃវិធានការវេចខ្ចប់ និងបិទផ្លាក

៦៦. ភាគីទាំងឡាយគួរពិចារណាលើការតាមដាន និងការវាយតម្លៃវិធានការវេចខ្ចប់ និងបិទផ្លាករបស់ខ្លួន ដើម្បីវាយតម្លៃពីឥទ្ធិពល ព្រមទាំងរិះរកចំនុចដែលត្រូវកែលំអ។ ការតាមដាន និងការវាយតម្លៃក៏រួមចំណែកផងដែរ ក្នុងអង្គនៃភស្តុតាងដែលអាចជួយដល់កិច្ចខិតខំប្រឹងប្រែងរបស់ភាគីទាំងឡាយ ក្នុងការអនុវត្តន៍ការវេចខ្ចប់ និងការបិទផ្លាក ។

៦៧. តាមដានការគោរពច្បាប់របស់ឧស្សាហកម្មថ្នាំជក់ គួរត្រូវផ្តួចផ្តើមឡើងជាបន្ទាន់ បន្ទាប់ពីវិធានការច្បាប់ចូលជាធរមាន និងគួរធ្វើឡើងជាបន្តបន្ទាប់រហូតទៅ។

### ឥទ្ធិពលទៅលើប្រជាពលរដ្ឋ

៦៨. វាជាការចាំបាច់ណាស់ ដែលត្រូវធ្វើការវាយតម្លៃពីឥទ្ធិពលនៃវិធានការវេចខ្ចប់ លើក្រុមគោលដៅ។ ភាគីទាំងឡាយ គួរពិចារណាលើទិដ្ឋភាពនៃវិធានការដូចជាៈ ភាពអាចសំគាល់បាន អាចយល់បាន អាចជឿជាក់បាន មានលក្ខណៈជាការផ្តល់ព័ត៌មាន ការចងចាំ និងការទាក់ទងជាលក្ខណៈបុគ្គលនៃបំរាមសុខភាព និងសារចំណេះដឹង និងការដឹងពីគ្រោះថ្នាក់ទាំងឡាយ ដែលផ្តោតទៅលើការផ្លាស់ប្តូរឥរិយាបទ និងការផ្លាស់ប្តូរអាកប្បកិរិយាជាក់ស្តែង ។

### ការវាយតម្លៃជាបឋម និងការតាមដាន

៦៩. ភាគីទាំងឡាយគួរពិចារណាការអនុម័តយុទ្ធសាស្ត្រ ដើម្បីវាយតម្លៃពីឥទ្ធិពលនៃវិធានការវេចខ្ចប់ និងបិទផ្លាក ទាំងមុន និងចន្លោះពេលជាទៀងទាត់ក្រោយពីការអនុវត្តន៍វិធានការនេះ ។

**ធនធាន**

៧០. វិសាលភាព និងភាពសាំញ៉ាំនៃសកម្មភាព ដើម្បីវាយតម្លៃពីឥទ្ធិពលនៃវិធានការវេចខ្ចប់ និងបិទផ្លាក នឹងមានលក្ខណៈផ្សេងពីគ្នាក្នុងចំណោមភាគីទាំងឡាយ ដោយផ្អែកលើគោលបំណង និងលទ្ធភាពនៃធនធាន និងភាពជំនាញ ។

**ការផ្សព្វផ្សាយ**

៧១. ភាគីទាំងឡាយគួរពិចារណាលើការបោះពុម្ពផ្សាយ ឬក៏ការបង្កលក្ខណៈងាយស្រួលដល់ភាគីទាំងឡាយ និងសាធារណៈជន នូវលទ្ធផលដែលប្រមូលបានមកពីការតាមដានការអនុវត្តន៍តាម និងការវាយតម្លៃឥទ្ធិពល ។

**កិច្ចសហប្រតិបត្តិការអន្តរជាតិ**

៧២. កិច្ចសហប្រតិបត្តិការមានសារសំខាន់ណាស់ ចំពោះការរីកចំរើនក្នុងតំបន់ដែលមានការផ្លាស់ប្តូរជាសារវ័ន្ត និងជាប់លាប់ក្នុងការត្រួតពិនិត្យថ្នាំជក់ ។ មាត្រាជាច្រើននៃអនុសញ្ញា ផ្តល់នូវការផ្លាស់ប្តូរចំណេះដឹង និងបទពិសោធន៍ក្នុងការលើកកំពស់ការរីកចំរើនក្នុងការអនុវត្តន៍ ដោយការផ្តោតជាពិសេសលើសេចក្តីត្រូវការនៃភាគីទាំងឡាយ ក្នុងប្រទេសកំពុងអភិវឌ្ឍន៍ និងក្នុងប្រទេសដែលមានសេដ្ឋកិច្ចស្ថិតក្នុងដំណាក់អន្តរកាល ។ កិច្ចសហប្រតិបត្តិការក្នុងចំណោមភាគីទាំងឡាយ ក្នុងការលើកកំពស់ការបង្វែរភាពជំនាញខាងបច្ចេកទេសវិទ្យាសាស្ត្រ និងច្បាប់ ហើយនិងបច្ចេកវិទ្យា ដូចបានទាមទារដោយមាត្រា ២២ នឹងពង្រឹងការអនុវត្តន៍មាត្រា១១ នៃអនុសញ្ញាជាសកល ។ ឧទាហរណ៍មួយនៃកិច្ចសហប្រតិបត្តិការនេះ គឺការផ្តល់អាជ្ញាប័ណ្ណយ៉ាងលឿន និងងាយស្រួល ដោយមិនគិតកំរៃ ពីភាគីទៅប្រទេសដែលកំពុងស្វែងរកប្រើប្រាស់បំរាមសុខភាព និងសារជារូបភាព ។ កិច្ចសហប្រតិបត្តិការអន្តរជាតិ ក៏អាចជួយផងដែរក្នុងការធានាដល់ការចែកចាយ ទូទាំងសកលលោក នូវព័ត៌មានដែលស៊ីសង្វាក់គ្នា និងត្រឹមត្រូវ ទាក់ទងទៅនឹងផលិតផលថ្នាំជក់ ។

៧៣. ភាគីទាំងឡាយ គួរតែស្វះស្វែងការចែករំលែកភាពជំនាញផ្អែកច្បាប់ និងភាពជំនាញផ្សេងទៀត ក្នុងការតបតទៅនឹងការតវ៉ារបស់ឧស្សាហកម្មថ្នាំជក់ ប្រឆាំងនឹងវិធានការវេចខ្ចប់ និងបិទផ្លាក ។

៧៤. ភាគីទាំងឡាយ គួរពិចារណាការពិនិត្យឡើងវិញនូវរបាយការណ៍របស់ភាគីដទៃទៀត ស្របតាមមាត្រា ២១ នៃអនុសញ្ញា ដើម្បីលើកកំពស់ចំណេះដឹងរបស់ពួកគេលើបទពិសោធន៍អន្តរជាតិ ទាក់ទិនទៅនឹងការវេចខ្ចប់ និងការបិទផ្លាក ។